**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៧.បប

# បទបញ្ជា

## ស្តីពី

## ការអនុវត្តផែនការស្តីពីការទប់ស្កាត់ និងដោះស្រាយបញ្ហា កូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ឆ្នាំ ២០១៦-២០១៩

ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព និងបទប្បញ្ញត្តិជាធរមាន ក៏ដូចជាថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងជីវភាពរស់នៅសុខសាន្តជូនប្រជាពលរដ្ឋ និងរក្សាបរិយាកាសល្អសម្រាប់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

ដើម្បីទប់ស្កាត់ និងដោះស្រាយអំពើញុះញង់ បោកប្រាស់ប្រជាពលរដ្ឋឱ្យចូលរួមសកម្មភាព អាណាធិបតេយ្យខុសច្បាប់ ការប្រព្រឹត្តអំពើហិង្សា បំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន និងទ្រព្យសម្បត្តិសាធារណៈ ក្នុងគោលដៅបង្កើតបដិវត្តន៍ពណ៌ បំផ្លាញសន្តិភាព ស្ថិរភាព និងប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់។

ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវខ្ពស់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ និងកងកម្លាំងមានសមត្ថកិច្ចគ្រប់ប្រភេទក្នុងការបំពេញភារកិច្ចទប់ស្កាត់ និងដោះស្រាយរាល់ករណីកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវបទបញ្ជា ដូចខាងក្រោម៖

១. ត្រូវបានដាក់ឱ្យអនុវត្តផែនការស្តីពីការទប់ស្កាត់ និងដោះស្រាយបញ្ហាកូដកម្ម បាតុកម្មឆ្នាំ២០១៦-២០១៩របស់គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា។

២. គណៈបញ្ជាការឯកភាព និងគណៈកម្មការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវមានផែនការណែនាំក្នុងភូមិសាស្ត្ររបស់ខ្លួន។ រាល់ករណីកូដកម្ម បាតុកម្មដែលកើតឡើងនៅតាមភូមិសាស្ត្រណា គណៈបញ្ជាការឯកភាព និងគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញានោះ ត្រូវទទួលខុសត្រូវដឹកនាំបញ្ជាដោះស្រាយរាល់ករណីជាក់ស្តែងនីមួយៗ។ គណៈបញ្ជាការឯកភាព និងគណៈកម្មការសម្រាប់ដោះស្រាយ បញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញាគ្រប់ថ្នាក់ត្រូវខិតខំដោះស្រាយឱ្យអស់លទ្ធភាព។ ក្នុងករណីដែលមិនអាចទប់ទល់បានទេ ត្រូវរាយការណ៍ជូនថ្នាក់លើផ្ទាល់របស់ខ្លួនដើម្បីសុំយោបល់ និងអន្តរាគមន៍តាមការចាំបាច់។

៣. អគ្គស្នងការនគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវមានផែនការណែនាំ ដើម្បីអនុវត្តភារកិច្ចនេះតាមសមត្ថកិច្ច និងតាមនីតិវិធីជាធរមាន។

៤. គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវមានវិធានការណែនាំដើម្បីអនុវត្តភារកិច្ចនេះតាមសមត្ថកិច្ចរៀងៗខ្លួន។

៥. គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា មានភារកិច្ចផ្សព្វផ្សាយតាមដានត្រួតពិនិត្យ និងចាត់ចែងអនុវត្តផែនការនេះតាមសមត្ថកិច្ចរបស់ខ្លួន ជាសេនាធិការរបស់រាជរដ្ឋាភិបាល។ ក្នុងករណីចាំបាច់ គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ត្រូវរាយការណ៍ជាបន្ទាន់ ដើម្បីសុំបទបញ្ជាដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល។

គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តបទបញ្ជានេះឱ្យបានម៉ឺងម៉ាត់បំផុត និងមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- រាជកិច្ច